១១២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តពោធិសាត់**
-សាលក្រមព្រហ្មទណ្ឌលេខ០៤(ផ)
ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០
-សំណុំរឿងព្រហ្មទណ្ឌលេខ១៩០
ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩

# សាលក្រមព្រហ្មទណ្ឌ

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តពោធិសាត់

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រិត្យលេខ០៦ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តពោធិសាត់ កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ ដែលមានសមាសភាពដូចតទៅ ៖

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តពោធិសាត់

**ចៅក្រមប្រឹក្សា**

-លោក [redacted] ចៅក្រមសាលាដំបូងខេត្តពោធិសាត់
-លោក [redacted] ចៅក្រមសាលាដំបូងខេត្តពោធិសាត់

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តពោធិសាត់

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តពោធិសាត់

**ដើម្បីជំនុំជម្រះលើជនជាប់ចោទ**

១-ឈ្មោះ [redacted] **មាត់** ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរឥស្លាម សាសនាឥស្លាម កើតនៅភូមិចុងខ្នុង ឃុំអូរសណ្ដាន់ ស្រុកក្រគរ ខេត្តពោធិសាត់ មុខរបរលក់ដូរ ទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តពោធិសាត់ ទោសពីមុន គ្មាន ។ ឪពុកឈ្មោះ [redacted] (ស្លាប់) ម្ដាយឈ្មោះ [redacted] (រស់) ប្រពន្ធឈ្មោះ [redacted] មានកូន០១នាក់ ។

២-ឈ្មោះ [redacted] **ឡេះ** ភេទប្រុស អាយុ៤៤ឆ្នាំ ជាតិខ្មែរឥស្លាម សាសនាឥស្លាម កើតនៅភូមិត្រពាំងខ្នុង ឃុំឈូកស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង មុខរបរធ្វើស្រែ ទីលំនៅបច្ចុប្បន្ន [redacted] ខេត្តពោធិសាត់ ទោសពីមុន គ្មាន ។ ឪពុកឈ្មោះ [redacted] (ស្លាប់) ម្ដាយឈ្មោះ [redacted] រស់) ប្រពន្ធឈ្មោះ [redacted] មានកូន០៧នាក់ ។

**ជាប់ចោទពីបទ** មនុស្សឃាដគិតទុកជាមុន ប្រព្រឹត្តនៅភូមិសាលាគំរូ សង្កាត់ព្រៃញី ក្រុងពោធិសាត់ ខេត្តពោធិសាត់ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

ជនជាប់ចោទទាំងពីរអមដោយលោក [redacted] **ស៊ីថាន់** ជាមេធាវីការពារសិទ្ធិជនជាប់ចោទ ។

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ៥០ឆ្នាំ នៅភូមិក្រាំងតាសែន សង្កាត់ព្រៃញី ក្រុងពោធិសាត់ ខេត្ត ពោធិសាត់ ដោយមានលោក [redacted] **ស៊ីមេត** ជាមេធាវីតំណាងដោយអាណត្តិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ។



Scanned by CamScanner

## ១១៣

ប្តឹងសុំឱ្យផ្តន្ទាទោសជនល្មើសតាមច្បាប់ និង ទារជម្ងឺចិត្តចំនួន ១០.០០០(ដប់ពាន់)ដុល្លាអាមេរិក ។

### អង្គហេតុ

កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ ជនរងគ្រោះឈ្មោះ[redacted] ម៉ាត់ ហៅ [redacted] ភេទប្រុស អាយុ៦០ឆ្នាំ បានធ្វើដំណើរមកពីលេងផ្ទះកូននៅភូមិចុងខ្លុង ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិសាត់ ដោយជិះម៉ូតូលើកំណាត់ផ្លូវជាតិលេខ៥ ឆ្ពោះមកទីរួមខេត្តពោធិសាត់ ។ លុះមកដល់ភូមិសាលាគំរូ សង្កាត់ព្រៃញី ក្រុងពោធិសាត់ ខេត្តពោធិសាត់ នៅវេលាម៉ោង១១ និង៣០នាទី មានជនល្មើសចំនួនពីរនាក់ជិះម៉ូតូឌុបគ្នាមកតាមក្រោយ មកដល់កៀកបានបាញ់ជនរងគ្រោះនឹងកាំភ្លើងខ្លីចំនួនមួយគ្រាប់ ត្រូវក្រោមឆ្អឹងជំនីខាងឆ្វេងបណ្តាលឱ្យរបួសធ្ងន់ និង បណ្តាលឱ្យស្លាប់ក្រោយពីបានសង្គ្រោះនៅមន្ទីរពេទ្យ ។

### នាពេលសវនាការ

-តាមអំណានកំណត់ហេតុស្តាប់ចម្លើយជនរងគ្រោះ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ (ឯកសារលេខ១០) ជនរងគ្រោះឈ្មោះ[redacted] ម៉ាត់ ហៅម៉ាត់យូន បានឆ្លើយប្រាប់មន្ត្រីនគរបាលយុត្តិធម៌ថា កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ ខ្លួនបានទៅលេងផ្ទះកូនស្រីឈ្មោះ[redacted]ស់ នៅភូមិចុងខ្លុង ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិសាត់ ក្រោយពីហូបបាយរួចនៅវេលាម៉ោងជាង១០ព្រឹក ខ្លួនបានជិះម៉ូតូឆ្ពោះមកភូមិសាលាគំរូដើម្បីមកយកអង្ករ ក្នុងពេលធ្វើដំណើរតាមផ្លូវខ្លួនឃើញឈ្មោះ ឡេះ ប្រពន្ធឈ្មោះកាស់ និងម្នាក់ទៀតឈ្មោះម៉ាត់ ប្រពន្ធឈ្មោះ ពាស់ ជិះម៉ូតូឌ្រីមពណ៌ខ្មៅឌុបគ្នាតាមពីក្រោយខ្លួន លុះមកដល់ចំណុចកើតហេតុនាភូមិសាលាគំរូ ជនទាំងពីរបានជិះមកកៀក រួចបាញ់កាំភ្លើងមកលើខ្លួនត្រូវក្រោមឆ្អឹងជំនីមួយគ្រាប់ តែខ្លួនមិនដួលទេ ខ្លួនបានជិះម៉ូតូចូលផ្ទះរបស់អ្នកភូមិក្បែរនោះដើម្បីឱ្យគេជួយ ។ ជនរងគ្រោះបញ្ជាក់ថា ជនល្មើសទាំងពីរនាក់ អ្នកបើកម៉ូតូពាក់មួកសុវត្ថិភាព ឯម្នាក់ជិះខាងក្រោយពាក់អាវធំ ក្រោយពីបាញ់រួចវាបានជិះម៉ូតូយ៉ាងលឿនទៅទិសខាងលិច ចំណែកខ្លួនមួយសន្ទុះក្រោយមកទើបឡានពេទ្យមកយកទៅសង្គ្រោះនៅមន្ទីរពេទ្យ ។

-តាមចម្លើយរបស់ឈ្មោះ[redacted] គង់ ជាប្រពន្ធជនរងគ្រោះបានបញ្ជាក់ថា ខ្លួនពុំបានដឹងថាអ្នកណាជាអ្នកបាញ់សម្លាប់ប្តីរបស់ខ្លួននោះទេ តែមុនពេលស្លាប់ខ្លួនបានឮប្តីរបស់ខ្លួននិយាយថា អ្នកដែលបាញ់គាត់គឺឈ្មោះ[redacted] ម៉ាត់ និងឈ្មោះ [redacted] ឡេះ ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted] ម៉ាត់ នាពេលសវនាការបានបញ្ជាក់ថា កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ ខ្លួនបានបើកឡានជូនប្រពន្ធទៅលក់ចានឆ្នាំងតាំងពីព្រឹកព្រលឹម លុះជូនរួចហើយខ្លួនបានត្រឡប់មកផ្ទះវិញដូចសព្វមួយដង ។[redacted]ម៉ាត់ បន្តថា នៅថ្ងៃដដែលនោះ ចន្លោះពីម៉ោង១០ព្រឹករហូតដល់ម៉ោង១២ថ្ងៃត្រង់ ខ្លួនមិនបានចេញទៅណាទេ គឺខ្លួននៅបោកខោអាវ ងូតទឹក ហូបបាយឯផ្ទះរបស់ខ្លួន បន្ទាប់មកចូលថ្វាយបង្គំព្រះនៅក្នុងព្រះវិហារឥស្លាម ដែលនៅក្បែរផ្ទះរបស់ខ្លួននោះ ។ [redacted]ម៉ាត់ បន្តទៀតថា នៅម៉ោង១២ជាង ពេលដែលខ្លួនចេញពីព្រះវិហារ ស្រាប់តែឃើញនគរបាលទៅហៅខ្លួនមកសាកសួរនៅប៉ុស្តិ៍នគរបាលអូរសណ្តាន់ ។ ក្រោយពីសាកសួររួចទើបខ្លួនដឹងថា ខ្លួនត្រូវគេចោទប្រកាន់ថាជាអ្នកសម្លាប់ឈ្មោះ[redacted]ម៉ាត់ ហៅម៉ាត់យូន រួមជាមួយឈ្មោះ[redacted] ឡេះ តាមពិតខ្លួនមិនបានដឹងរឿងអ្វីទាំងអស់ ព្រោះពេលកើតហេតុដែលគេចោទប្រកាន់នោះ ខ្លួននៅឯព្រះវិហារដែលមានចម្ងាយឆ្ងាយពីកន្លែងកើតហេតុ ហើយខ្លួនមានសាក្សីជាច្រើននាក់ដឹងឮ ទើបក្រោយពីសាកសួរចប់សមត្ថកិច្ចបានអនុញ្ញាតិឱ្យខ្លួនត្រឡប់មកផ្ទះវិញ ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ឡេះ នាពេលសវនាការបានបញ្ជាក់ថា កាលពីថ្ងៃកើតហេតុថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ ចន្លោះពីម៉ោង១១ទៅម៉ោង១២ថ្ងៃត្រង់ ខ្លួនទៅផឹកកាហ្វេក្នុងតៀមកាហ្វេក្បែរសាលាឃុំអូរសណ្តាន់ឯណោះ ដោយមានសាក្សីជាច្រើននាក់ដែលផឹកកាហ្វេជាមួយគ្នាបានឃើញ ជាពិសេសគឺឈ្មោះ[redacted]ណាក់ ជានាយប៉ុស្តិ៍នគរបាលក៏នៅផឹកកាហ្វេទីនោះដែរ គឺមានទីតាំងឆ្ងាយពីកន្លែងកើតហេតុណាស់ ។ ក្រោយពេលកើតហេតុខ្លួនមិនបានគេចទៅណាទេ គឺបានចូលទៅឆ្លើយបំភ្លឺតាមការអញ្ជើញរបស់សមត្ថកិច្ច ហើយសមត្ថកិច្ចក៏ពុំបានឃាត់ខ្លួនដែរព្រោះខ្លួនមិនបានប្រព្រឹត្ត ។



Scanned by CamScanner

-តាមចម្លើយរបស់សមត្ថកិច្ចឈ្មោះ[redacted]ណាក់ នាយប៉ុស្តិ៍នគរបាលឃុំអូរសណ្តាន់ បានបញ្ជាក់ថា នៅពេលកើតហេតុ ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០០៩ ខ្លួនបានទៅផឹកកាហ្វេនៅតៀមកាហ្វេរបស់ឈ្មោះ[redacted]ហួន ក្បែរសាលាឃុំអូរសណ្តាន់ នាវេលាម៉ោង១១រហូតដល់ម៉ោង១១និង៥៩នាទីទើបចេញពីហាងកាហ្វេ ពេលនោះលោកអធិការស្រុកក្រគរ បានទូរស័ព្ទប្រាប់ខ្លួនថាឈ្មោះ[redacted]ម៉ាត់ និង [redacted]ឡេះ ជាអ្នកបាញ់សម្លាប់ឈ្មោះតាម៉ាត់ហួន និង បានបញ្ជាឱ្យខ្លួនទៅផ្ទះរបស់ជនរងគ្រោះដើម្បីសួររកផ្ទះរបស់ឈ្មោះទាំងពីរ ពេលនោះខ្លួនក៏វាយការណ៍ប្រាប់វិញថា ខ្លួនទើបតែបែកពីឈ្មោះ[redacted] ឡេះ ពីកន្លែងផឹកកាហ្វេនៅមុននេះបន្តិច បន្ទាប់មកខ្លួនក៏ធ្វើដំណើរទៅរកផ្ទះរបស់[redacted] ម៉ាត់ និងបានប្រាប់ឈ្មោះ[redacted]ម៉ាត់ ឱ្យមកប៉ុស្តិ៍អូរសណ្តាន់ដើម្បីសាកសួរ ។ លោក[redacted]ណាក់ បានបញ្ជាក់ទៀតថា រឿងបាញ់សម្លាប់មនុស្ស ខ្លួនមិនបានដឹងទេ ប៉ុន្តែចន្លោះពីម៉ោង១១ដល់ម៉ោង១១និង៥៩នាទីថ្ងៃត្រង់នាថ្ងៃកើតហេតុនោះ ខ្លួនឃើញឈ្មោះ [redacted]ឡេះ នៅផឹកកាហ្វេជាមួយខ្លួន រួមគ្នាជាមួយឈ្មោះ[redacted]សួន សមាជិកក្រុមប្រឹក្សាឃុំអូរសណ្តាន់ ឈ្មោះ[redacted]យ៉ុង ស្មៀនឃុំអូរសណ្តាន់ និង ឈ្មោះ [redacted]សុជាតិ ជំនួយការស្មៀនឃុំ រីឯឈ្មោះ[redacted]ម៉ាត់ ខ្លួនឃើញឈ្មោះនេះនៅផ្ទះក្នុងពេលដែលខ្លួនទៅរកតាមបញ្ជា របស់លោកអធិការនគរបាលស្រុកក្រគរនោះ ។

-តាមអំណានកំណត់ហេតុសួរចម្លើយរបស់សាក្សីបំភ្លឺឈ្មោះ [redacted]សម្បត្តិ ជំទប់ទី១ឃុំអូរសណ្តាន់ និង ឈ្មោះ [redacted]យ៉ុង ស្មៀនឃុំអូរសណ្តាន់ (ឯកសារ៤០ . ៤១) បានឆ្លើយប្រហាក់ប្រហែលគ្នាបញ្ជាក់ថា នៅថ្ងៃកើតហេតុខ្លួនមិនចាំថ្ងៃទេតែក្នុងខែមិថុនា ឆ្នាំ២០០៩ ខ្លួនពិតជាបានរួមតុកាហ្វេជាមួយឈ្មោះ[redacted] ឡេះ នៅវេលាម៉ោង១១ ពេលដែលខ្លួនចេញពីធ្វើការបន្ទាប់មកទើបបែកគ្នាទៅផ្ទះមែន ប៉ុន្តែខ្លួនមិនបានដឹងអំពីរឿងឃាតកម្មនោះទេនាពេលនោះ ។ ឈ្មោះ[redacted]សម្បត្តិបានបញ្ជាក់ថា ចម្ងាយពីតៀមកាហ្វេទៅកន្លែងកើតហេតុនៅភូមិសាលាគំរូ មានចម្ងាយប្រហែលជាង២០គីឡូម៉ែត្រពីគ្នា បើធ្វើដំណើរដោយម៉ូតូត្រូវប្រើពេលប្រហែល៤០នាទីទើបមកដល់ ។

-តាមអំណានកំណត់ហេតុស្តាប់ការបំភ្លឺរបស់ឈ្មោះ[redacted] ធន (ឯកសារលេខ៩) បានឆ្លើយបញ្ជាក់ថា កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ វេលាម៉ោង១១និង៣០នាទី ខ្លួនបានឮសូរសំលេងផ្ទុះ ខ្លួនស្មានថាជាសំលេងឡានបែកកង់ ប្រហែលប្រាំនាទីក្រោយមកស្រាប់តែឃើញ បុរសចំណាស់ម្នាក់យកម៉ូតូមកបញ្ឈរនៅមុខផ្ទះខ្លួន រួចដើរចូលមកប្រាប់ខ្លួនថា " ម៉ូតូបែកកង់ហើយគ្រូសខ្មាតត្រូវបណ្តាលឱ្យរបួស សុំឱ្យខ្លួនជួយមើលផង " ដោយឃើញឈាមហូរច្រើនពេក ខ្លួនបានទូរស័ព្ទហៅនគរបាលឱ្យជួយមើល ពេលនោះជនរងគ្រោះបានដើរទៅផ្លូវជាតិវិញ ក្រោយមកទើបរថយន្តសង្គ្រោះមកដល់ ។

-តាមអំណានកំណត់ហេតុស្តាប់ការបំភ្លឺ របស់ឈ្មោះ[redacted]សុភា (ឯកសារលេខ៨) បានឆ្លើយបញ្ជាក់ថា កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ វេលាម៉ោង១១និង៣០នាទី នាងកំពុងអង្គុយលោតអង្រឹងកូន នាងបានឃើញម៉ូតូមួយគ្រឿងជិះម្នាក់ឯងពីកើតទៅលិច ក្នុងពេលនោះដែរនាងបានឃើញម៉ូតូមួយគ្រឿងទៀតជិះឌុបគ្នាពីរនាក់មកតាមក្រោយ មកដល់ប្រហែលបីម៉ែត្រ នាងឃើញជនដែលជិះខាងក្រោយ ដកកាំភ្លើងខ្លីបាញ់សំដៅជនរងគ្រោះដែលជិះម៉ូតូម្នាក់ឯងខាងមុខ រួចជិះរត់ទៅទិសខាងលិចបាត់ទៅ ឯជនរងគ្រោះជិះបានប្រហែល១០០ម៉ែត្របានឈប់ម៉ូតូរួចដើរចូលទៅផ្ទះឈ្មោះ[redacted]ធន ។

-ក្រោយពីបានស្បថរួច សាក្សីឈ្មោះ[redacted] ស្លេះ ឈ្មោះ[redacted] ការ៉ា និង ឈ្មោះ[redacted]ម៉ាត់ បានឆ្លើយប្រហាក់ប្រហែលគ្នាថា ខ្លួនមានផ្ទះនៅក្បែរផ្ទះរបស់ជនជាប់ចោទ[redacted] ម៉ាត់ នៅថ្ងៃកើតហេតុនាវេលាម៉ោង១០កន្លះព្រឹកខ្លួនបានឃើញ [redacted] ម៉ាត់ បោកខោអាវនៅក្បែរផ្ទះ បន្ទាប់ពីបោកខោអាវរួច បានចូលទៅថ្វាយបង្គំព្រះទាំងអស់គ្នា លុះដល់ម៉ោងប្រហែល១២ថ្ងៃត្រង់ស្រាប់តែឃើញនគរបាលប៉ុស្តិ៍មកហៅ[redacted] ម៉ាត់ ទៅប៉ុស្តិ៍អូរសណ្តាន់ ។ សាក្សីបានបញ្ជាក់ថា រឿងធ្វើឃាតមនុស្សខ្លួនមិនបានដឹងទេ ប៉ុន្តែគ្រាន់តែដឹងថា ចន្លោះពីម៉ោង១០កន្លះរហូតដល់ម៉ោង១២ថ្ងៃត្រង់ថ្ងៃកើតហេតុ ឈ្មោះ[redacted] ម៉ាត់ នៅឯផ្ទះ និង ទៅថ្វាយបង្គំព្រះឯវិហារឥស្លាមដែលមានចម្ងាយឆ្ងាយពីកន្លែងកើតហេតុ ។

-តាមចម្លើយសាក្សីជនរងគ្រោះឈ្មោះ [redacted]វ៉ាន់ស៊ី ឈ្មោះ [redacted]ម៉ាស់ និង ឈ្មោះ[redacted] សាយ ដែលត្រូវជាកូនជាចៅនិង

ជាសាច់ញាតិជនរងគ្រោះ បានឆ្លើយប្រហាក់ប្រហែលគ្នាថា ខ្លួនមិនបានឃើញពេលកើតហេតុទេ តែខ្លួនបានឮជនរងគ្រោះមុនពេលស្លាប់និយាយប្រាប់ថា ជនល្មើសដែលជាអ្នកបាញ់គាត់ គឺឈ្មោះ[redacted]ម៉ាត់ និង ឈ្មោះ[redacted] ឡេះ នៅចំពោះមុខតុលាការនេះតែម្តង ។

តំណាងអយ្យការសន្និដ្ឋានថា រក្សាការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted]ម៉ាត់ និង ឈ្មោះ [redacted] ឡេះ ពីបទមនុស្សឃាដគិតទុកជាមុន ប្រព្រឹត្តនៅភូមិសាលាត្បូ សង្កាត់ព្រៃញី ក្រុងពោធិសាត់ ខេត្តពោធិសាត់ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាម មាត្រា៣ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ។

មេធាវីតំណាងដោយអាណត្តិរបស់ដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋានថា សូមឯកភាពតាមតំណាងអយ្យការចំពោះការរក្សាការចោទប្រកាន់លើជនជាប់ចោទ ដោយសំអាងលើសំដីជនរងគ្រោះ មុនពេលស្លាប់បានប្រាប់សមត្ថកិច្ចយ៉ាងច្បាស់ថា គឺជនជាប់ចោទឯល [redacted] និង[redacted] ឡេះ ដែលជាអ្នកបាញ់ជនរងគ្រោះ ហេតុនេះសូមឱ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ និង សុំទារជម្ងឺចិត្តចំនួន១០.០០០(ដប់ពាន់)ដុល្លាអាមេរិក ។

មេធាវីការពារសិទ្ធិជនជាប់ចោទ បាធ្វើសេចក្តីសន្និដ្ឋានថា ពេលកើតហេតុថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ ចន្លោះពីម៉ោង ១១ទៅ១២ថ្ងៃត្រង់ ជនជាប់ចោទទាំងពីរនៅកន្លែងខុស១ពីគ្នា គឺ[redacted] ម៉ាត់ នៅឯផ្ទះនិងនៅសូត្រធម៌ឯវិហារឥស្លាម រីឯឈ្មោះ[redacted]ឡេះ នៅហាងកាហ្វេ សុទ្ធតែមានចម្ងាយឆ្ងាយពីកន្លែងកើតហេតុ និងមានសាក្សីបញ្ជាក់ការពិតរៀង១ខ្លួន ដែលបញ្ជាក់ថាជនជាប់ចោទមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ សូមឱ្យតុលាការលើកលែងការចោទប្រកាន់តាមច្បាប់ ។

## សំអាងហេតុ

១-ចម្លើយរបស់ជនរងគ្រោ[redacted]ម៉ាត់ ហៅម៉ាត់យូន នៅក្រោយពេលកើតហេតុភ្លាម១មានស្មារតីរឹងប៉ឹង បានឈប់ម៉ូតូរួចចូលទៅប្រាប់ សាក្សីឈ្មោះ[redacted]ចន ថា " ម៉ូតូបែកកង់ហើយ ត្រូវខ្មាតត្រូវខ្លួនបណ្តាលឱ្យរបួស សុំឱ្យ ជួយមើលផង " ជាចម្លើយដែលផ្ទុយពីចម្លើយរបស់ជនរងគ្រោះរូបនេះនៅមន្ទីរពេទ្យ ដែលបានឆ្លើយប្រាប់ចំឈ្មោះជនជាប់ចោទ ដែលជាអ្នកបាញ់ខ្លួន ចំណុចនេះអាចឱ្យតុលាការពិចារណាបាន ។

២-ចម្លើយសាក្សីជនរងគ្រោះ គឺសុទ្ធតែបានដឹងដោយសារឮជនរងគ្រោះនិយាយមុនពេលស្លាប់នោះទាំងអស់ ចំណុចនេះអាចឱ្យតុលាការពិចារណាតែទៅលើចម្លើយ របស់ជនរងគ្រោះនោះតែប៉ុណ្ណោះ ។

៣-លើកំណាត់ផ្លូវជាតិលេខ៥ ចម្ងាយពីកន្លែងកើតហេតុត្រង់ចំណុចភូមិសាលាត្បូ សង្កាត់ព្រៃញី ក្រុងពោធិសាត់ ខេត្តពោធិសាត់ ទៅកន្លែងតៀមកាហ្វេដែលជនជាប់ចោទ[redacted] ឡេះ ជីកកាហ្វេ និង ផ្ទះរបស់ជនជាប់ចោទ[redacted] ម៉ាត់ មានចម្ងាយជាង២០គីឡូម៉ែត្រពីគ្នា ចំណុចនេះបញ្ជាក់ថា ជនល្មើសក្រោយពេលប្រព្រឹត្តបទល្មើសរួចមិនអាចវិលត្រឡប់ទៅក្រោយវិញទាន់បានទេ ។ម្យ៉ាងទៀត សាក្សីឈ្មោះ[redacted]សុភា បានឆ្លើយបញ្ជាក់ថា ក្រោយពេលបាញ់រួចជនល្មើសជិះម៉ូតូទៅទិសខាងលិច មិនបានត្រឡប់ទៅក្រោយវិញ(ទិសខាងកើត)ជាកន្លែងជនសង្ស័យស្ថិតនៅ ។

៤-ការអះអាងរបស់សាក្សីជនរងគ្រោះ មិនមានភាពស៊ីសង្វាក់ទៅនឹងសាក្សីឈ្មោះ[redacted]ចន និង[redacted]សុភា ដែលបានឃើញហេតុការណ៍ផ្ទាល់ភ្នែកនោះឡើយ ។

៥-ចម្លើយរបស់ជនជាប់ចោទទាំងពីរដោះសារថា ខ្លួនមិនបានប្រព្រឹត្តបទល្មើសទេ ព្រោះពេលកើតហេតុខ្លួនស្ថិតនៅឯផ្ទះរបស់ខ្លួន ជាចម្លើយដែលអាចឱ្យតុលាការពិចារណាបាន ព្រោះមានសាក្សីមកបញ្ជាក់ច្បាស់លាស់ ជាពិសេសសាក្សីឈ្មោះ[redacted]ណាក់ ជានាយប៉ុស្តិ៍នគរបាលឃុំអូរសណ្តាន់ ដែលទទួលបន្ទុកឱ្យស្វែងរកជនជាប់ចោទ ហើយក្នុងពេលដែលទទួលបទបញ្ជាតាមទូរស័ព្ទនោះ [redacted]ណាក់ កំពុងស្ថិតនៅជាមួយជនជាប់ចោទតែម្តង ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថាជនជាប់ចោទមិនបានទៅប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់នោះទេ ។



Scanned by CamScanner

៦- តំណាងអយ្យការរក្សាការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ម៉ាត់ និង ឈ្មោះ [redacted] ឡេះ ពីបទមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិសាលាកំរូ សង្កាត់ព្រៃញី ក្រុងពោធិសាត់ ខេត្តពោធិសាត់ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាម មាត្រា៣ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ចំណុចនេះតុលាការ នឹង ពិចារណាទៅលើធាតុផ្សំនៃបទល្មើស ។

៧-តាមឯកសារភស្តុតាង និង ចម្លើយសាក្សី សុទ្ធតែបញ្ជាក់យ៉ាងច្បាស់ថា បទល្មើសកើតឡើងនៅវេលាម៉ោង១១និង៣០នាទីថ្ងៃត្រង់ ចំណុចនេះ អាចឱ្យតុលាការពិចារណាទៅលើវត្តមានរបស់ជនជាប់ចោទទាំងពីរនាក់ ដែលមានវត្តមាននៅកន្លែងផ្សេង១ពីគ្នា និងមានចម្ងាយឆ្ងាយពីកន្លែងកើតហេតុ ។

៨-គ្មានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ម៉ាត់ និង ឈ្មោះ [redacted] ម៉ាត់ ពីបទ មនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិសាលាកំរូ សង្កាត់ព្រៃញី ក្រុងពោធិសាត់ ខេត្តពោធិសាត់ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាម មាត្រា៣ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋនោះទេ ដោយវិមតិសង្ស័យត្រូវបានជា ប្រយោជន៍ដល់ជនជាប់ចោទ ស្របតាមមាត្រា៣៨នៃច្បាប់រដ្ឋធម្មនុញ្ញ ។

៩-ការប្តឹងទាមទារជម្ងឺចិត្តរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] គង់ ត្រូវជាប្រពន្ធជនរងគ្រោះ ចំនួន១០.០០០ (ដប់ពាន់) ដុល្លារអាមេរិក ពីជនជាប់ចោទឈ្មោះ [redacted] ម៉ាត់ និង ឈ្មោះ [redacted] ឡេះ នោះ មានលក្ខណៈត្រឹមត្រូវតាមទំរង់តែខុសទៅនឹងគតិច្បាប់ ។

ដោយផ្អែកតាមកថាខណ្ឌចុងក្រោយនៃមាត្រា៣៩០នៃក្រមនីតិវិធីប្រហ្មទណ្ឌឆ្នាំ២០០៧

## តុលាការខេត្តពោធិសាត់សំរេច

១-អោយឈ្មោះ [redacted] **ម៉ាត់** និង [redacted] **ឡេះ** រួចខ្លួនពីបទចោទពីបទ មនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិសាលាកំរូ សង្កាត់ព្រៃញី ក្រុងពោធិសាត់ ខេត្តពោធិសាត់ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣ នៃច្បាប់ស្តីពីស្ថានទំងន់ ទោសនៃបទឧក្រិដ្ឋ ។

២-លើកលែងការប្តឹងទាមទារជម្ងឺចិត្ត របស់អ្នកតំណាងដោយអាណត្តិដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **គង់** ចំនួន ១០.០០០(ដប់ពាន់)ដុល្លារអាមេរិក ពីជនជាប់ចោទឈ្មោះ [redacted] **ម៉ាត់** និង [redacted] **ឡេះ** ដោយខុសទៅនឹងគតិច្បាប់ ។

៣-សាលក្រមនេះជំនុំជំរះនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទ និង អ្នកតំណាងដោយអាណត្តិដើមបណ្តឹងរដ្ឋប្បវេណី និង ប្រកាសជាសាធារណៈនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១០ កំបាំងមុខជនជាប់ចោទ និង អ្នកតំណាងដោយអាណត្តិដើមបណ្តឹងរដ្ឋប្បវេណី ។

បើកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ** [redacted]

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** [redacted]



Scanned by CamScanner